**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាខេត្តតាកែវ**

លេខ ២៦៣ សខល

តាកែវ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៣

## សេចក្តីជូនដំណឹង
## ស្តីពី
## ការរំលឹកការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១៣

**រដ្ឋបាលខេត្តតាកែវ** មានកិត្តិយសសូមជំរាបជូនដំណឹងដល់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក-លោកស្រី ជាម្ចាស់រថយន្តដឹកជញ្ជូនគ្រប់ប្រភេទទាំងអស់ ដែលស្ថិតនៅក្នុងខេត្តតាកែវ សូមមេត្តាជ្រាបថា ៖ ចាប់តាំងពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីជូនដំណឹងលេខ ០០៥ សហវ.ពដ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១៣មក រហូតមកដល់ពេលនេះ **រដ្ឋបាលខេត្ត** បានពិនិត្យឃើញថា ឯកឧត្តម លោកជំទាវ លោក-លោកស្រី ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូនមួយចំនួនធំ បានអញ្ជើញមកបំពេញកាតព្វកិច្ចបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសំរាប់ឆ្នាំ២០១៣យ៉ាងសស្រាក់សស្រាំ។ ប៉ុន្តែទន្ទឹមនឹងនោះ ក៏នៅមានម្ចាស់មធ្យោបាយដឹកជញ្ជូនមួយចំនួន នៅមិនទាន់បានអញ្ជើញមកប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១៣នេះនៅឡើយ។

អាស្រ័យហេតុនេះ **រដ្ឋបាលខេត្ត** សូមធ្វើការប្រកាសជូនដំណឹងរំលឹកជាថ្មីម្តងទៀត ដល់ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក-លោកស្រី ជាម្ចាស់រថយន្តដឹកជញ្ជូនគ្រប់ប្រភេទទាំងអស់ ដែលនៅពុំទាន់បានអញ្ជើញមកប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០១៣នេះនៅឡើយនោះ សូមមេត្តាប្រញាប់ប្រញាល់រូសរាន់ អញ្ជើញទៅបង់ពន្ធនៅសាខាពន្ធដារខេត្ត និងនៅតាមទីស្នាក់ការពន្ធដារគ្រប់ស្រុក-ក្រុង អោយបានមុនថ្ងៃ**ទី ១៥ ខែកក្កដា ឆ្នាំ ២០១៣** តាមកាលកំណត់ ដើម្បីជៀសវាងនូវបាតុភាពកកស្ទះសំរុកមកបង់ពន្ធក្នុងថ្ងៃបញ្ចប់ចុងក្រោយនៃការផុតកំណត់ថ្ងៃបង់ពន្ធ។

ចំពោះទោចក្រយានយន្ត និងត្រីចក្រយានយន្តបំពាក់ដោយម៉ាស៊ីនម៉ូតូ ម្ចាស់យានយន្តទាំងនោះត្រូវទៅទិញបណ្ណបង់ពន្ធ នៅតាមសាខា ការិយាល័យស្រុក និងប៉ុស្តិ៍សេវាកម្មរបស់ធនាគាអេស៊ីលីដា។

**ចាប់ពីថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៣**តទៅ ចំពោះមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទទាំងឡាយណាដែលមិនបានមកបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសំរាប់ឆ្នាំ២០១៣អោយបានទាន់ពេលវេលាតាមកាលកំណត់ខាងលើនេះទេ នឹងត្រូវទទួលរងការផាកពិន័យបន្ថែមចំនួនមួយដង ស្មើនឹងប្រាក់ពន្ធដែលត្រូវបង់។

**រដ្ឋបាលខេត្តតាកែវ** សង្ឃឹមនិងជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក-លោកស្រី ជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងអស់ ពិតជាបានយល់ និងយកចិត្តទុកដាក់ក្នុងការបំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋអោយបានគ្រប់ៗគ្នាជាពុំខានឡើយ។

**អភិបាលខេត្ត**

**ស្រី បេន**

***<u>ចម្លងជូន:</u>***

*-ក្រសួងមហាផ្ទៃ*
*-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*-អគ្គនាយកដ្ឋានពន្ធដារ*
*"<u>ដើម្បីជូនជ្រាប</u>"*
*-លោក-លោកស្រីប្រធាន មន្ទីរ-អង្គភាពជុំវិញខេត្ត*
*- លោក-លោកស្រីអភិបាលគ្រប់ស្រុក-ក្រុង*
*-លោក-លោកស្រីមេឃុំ. ចៅសង្កាត់ គ្រប់ឃុំ-សង្កាត់*
*"<u>ដើម្បីជួយផ្សព្វផ្សាយនិងសហការអនុវត្ត</u>"*
*-គ្រប់ស្ថានីយវិទ្យុក្នុងខេត្ត*
*"<u>ដើម្បីជួយផ្សព្វផ្សាយ</u>"*
*-ឯកសារ-កាលប្បវត្តិ*